Notice
Can't identify browser version. Agent: Mozilla/5.0 (Macintosh; Intel Mac OS X) AppleWebKit/534.34 (KHTML, like Gecko) Qt/4.8.7 Safari/534.34

# បច្ចុប្បន្នភាពនៃជំងឺកូរូណាថ្មី COVID-19 នៅប្រទេសកម្ពុជា

សំរាប់ព័ត៌មានលំអិត សូមចុចមកលេខ 115

**COVID-19 Updated 01-04-2020**

រហូតម៉ោង ៩ៈ00 នាទីព្រឹក ថ្ងៃទី ១ មេសា ២០២០ យើងពុំរកឃើញអ្នកជំងឺ COVID-19 ថ្មីទេ ។ ប្រទេសយើងមានចំនួន ១០៩ ករណី និង បានព្យាបាលជាសះស្បើយចំនួន ២ករណីទៀត សរុប ២៥នាក់ ស្លាប់គ្មាន ។ យើងពុំទាន់រកឃើញភស្តុតាងបញ្ជាក់ថា មានការឆ្លងក្នុងសហគមន៍ នៅឡើយទេ តែលទ្ធភាពនឹងអាចកើតមានឡើង ។
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥
http://covid19-map.cdcmoh.gov.kh
អរគុណ inSTEDD




Read more: បច្ចុប្បន្នភាពនៃជំងឺកូរូណាថ្មី COVID-19 នៅប្រទេសកម្ពុជា

# នីតិវិធីដាក់ខ្លួន អោយនៅដាច់ដោយឡែក ក្នុងរយៈពេល១៤ថ្ងៃ ដើម្បីបង្ការ និងទប់ស្កាត់ជំងឺកូវីត១៩ នៅតាមផ្ទះជាលក្ខណៈបុគ្គល

***Updated: 31/March/2020***

សូមបងប្អូនដែលទើបធ្វើដំណើរ ត្រលប់ពីបរទេសទាំងអស់ សូមមេត្តាដាក់ខ្លួនឯង ឲ្យនៅដាច់ដោយឡែក ចំនួន១៤ថ្ងៃ និងតាមដានសុខភាព បើមានចេញរោគសញ្ញា សូមពិគ្រោះជំងឺជាមួយទូរស័ព្ទលេខ ១១៥ ។ សូមអានសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ។




# សារអប់រំទាក់ទងនឹងកូវី ១៩

***Updated: 31/March/2020***

ការកាត់បន្ថយហានិភ័យពីការឆ្លងកូវីត១៩ (COVID19) ដោយវិធីដំសាមញ្ញដូចខាងក្រោមៈ

ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥







# សូមសំដែងនូវការកោតសសើរ និងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅជូនចំពោះ

# សប្បុរសជនវេជ្ជបណ្ឌិតជំនាន់ទី២០

***Date: 31/March/2020***

 

នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
សូមសំដែងនូវការកោតសសើរ និងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅជូនចំពោះ សប្បុរសជនវេជ្ជបណ្ឌិតជំនាន់ទី២០
ដែលបានជួយឧបត្ថម្ភថវិកាដល់មន្រ្តីទទួលបន្ទុកតាមដាន ស្វែងរក ករណីសង្ស័យ តាមដានសុខភាពអ្នកប៉ះពាល់ ជំងឺកូវីដ១៩ និងមន្រ្តីទូរស័ព្ទទាន់ហេតុការណ៍ ១១៥ (២៤ម៉ោង/៧ថ្ងៃ) ចំនួន 1,000 $ (មួយពាន់ដុល្លាអាមេរិក) ដើម្បីលើកទឹកចិត្ត និងរួមចំណែកក្នុងការប្រយុទ្ធ និងទប់ស្កាត់ជំងឺកូវីដ១៩

សូមប្រសិទ្ធពរបវរសួស្តី មហាប្រសើរជូនដល់សប្បុរសធម៌ វេជ្ជបណ្ឌិតជំនាន់ទី២០ ទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# ទូរស័ព្ទទាន់ហេតុការណ៍ ១១៥ របស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង

***Date: 31/March/2020***



***Date: 08/February/2020***



យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ដល់និយ័តករទូរគមនាគមន៍កម្ពុជា និងក្រុមហ៊ុនទូរស័ព្ទចល័តទាំងអស់
ដែលបានអនុញ្ញាតអោយទូរស័ព្ទទៅលេខ ១១៥ ដោយមិនគិតថ្លៃ និងមិនមានឧបសគ្គ និងសូមពង្រីកវិសាលភាពទូរស័ព្ទ ចូលពី ៣០នាក់ក្នុងពេលតែមួយ ទៅ១២០នាក់ក្នុងពេលតែមួយ ដើម្បីជៀសវាងអាកខាន ពេលតេលើសកំនត់។ ទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ជាប្រព័ន្ធទូរស័ព្ទ ដែលត្រូវបានអភិវឌ្ឍន៏ទៅជាបច្ចេកវិទ្យាទំនើប និងសំរាប់ផ្តល់សេវា ជូនប្រជាពលរដ្ឋទូទាំងប្រទេសនូវៈ
១. ចំណេះដឹងទាក់ទងនឹង ជំងឺកូរ៉ូណាវីរុសប្រភេទថ្មី និងជំងឺឆ្លងផ្សេងៗទៀត
២. អាចរាយការណ៏ករណីជំងឺសង្ស័យ និងកើតឡើងច្រើនខុសធម្មតា ក្នុងទីតាំងណាមួយ
៣. អាចសួរពត៏មាន ឬចំណេះដឹងបន្ថែម ទាក់ទងនឹងជំងឺកូរ៉ូណា វីរុសប្រភេទថ្មី និងជំងឺឆ្លងផ្សេងៗទៀត
៤. យើងមានសហការីជំនាញសុខាភិបាល ១០រូបចាំទទួលទូរស័ព្ទ ដោយប្រើបច្ចេកវិទ្យា ប្រព័ន្ធបញ្ជូនទៅទូរស័ព្ទដៃរបស់គ្រូពេទ្យទាំង១០នាក់ (Calling Forward System)
អរគុណ មន្រ្តីនាញ IT នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
អរគុណ និយ័តករទូរគមនាគមន៏កម្ពុជា
អរគុណ ក្រុមហ៊ុនទូរស័ព្ទចល័តកម្ពុជាទាំងអស់
អរគុណ អង្គការ Instedd




- សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះ ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី"
- សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅជូនចំពោះ សប្បុរសជន ដែលបានឧបត្ថម្ភថវិកា ដល់មន្រ្តីទទួលបន្ទុក ទូរស័ព្ទទាន់ហេតុការណ៍ ១១៥ និងមន្រ្តីនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
- មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឆ្លងតាមរយៈដំណក់ទឹកតូចៗ ដែលខ្ចាតចេញមកក្រៅ តាមរយៈការក្អកឬកណ្តាស់
- លេខ ១១៥ មានអ្នកទូរស័ព្ទចូលរហូតដល់ ជាង៩៣ម៉ឺននាក់ គិតចាប់ពីពេលរកឃើញកូវិត១៩ ករណីទី១មក

Page 1 of 64

Home

Press Release
- Avian Influenza
- SARS
- Severe Watery Diarrhea
- Swine Influenza

- Other Disease
- MERS

Bulletins

- Year 9 (2012)
- Year 8 (2011)
- Year 7 (2010)
- Year 6 (2009)
- Monthly respiratory buttletin
  - Year 2014
  - Year 2015
  - Year 2016
  - Year 2017

IEC material and documents

- Posters
- Booklets
- Radio Spot
- TV Spots
- Leaflet
- National Guideline, Policy, and Strategy

Applied epidemiology training

- Course detail
- Team and advisory board
- First cohort (2011)
- Second cohort (2012)
- Documents and forms

Collaborative Projects with Hopital Service

## Latest Articles

- បច្ចុប្បន្នភាពនៃជំងឺកូរូណាថ្មី COVID-19 នៅប្រទេសកម្ពុជា
- នីតិវិធីដាក់ខ្លួន អោយនៅដាច់ដោយឡែក ក្នុងរយៈពេល១៤ថ្ងៃ ដើម្បីបង្ការ និងទប់ស្កាត់ជំងឺកូវីត១៩ នៅតាមផ្ទះជាលក្ខណៈបុគ្គល
- សារអប់រំទាក់ទងនឹងកូវី ១៩
- សូមសំដែងនូវការកោតសសើរ និងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅជូនចំពោះ សប្បុរសជនវេជ្ជបណ្ឌិតជំនាន់ទី២០
- ទូរស័ព្ទទាន់ហេតុការណ៍ ១១៥ របស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង

## Login Form

User Name

Password

Remember Me

Log in

Forgot your username?
Forgot your password?

## Visitors Counter

| | |
|---|---|
| Today | 1728 |
| Yesterday | 2810 |
| This week | 7603 |
| This month | 1728 |
| Total | 998082 |

Powered by CoalaWeb

© 2020 CDC Department Website